# សន្លឹកព័ត៌មានសាធារណៈ

Ottawa County Health Department

## គ្រីពតូស្ពោរីឌីយ៉ូស៊ីស [CRYTOSPORIDIUM]

### តើ គ្រីពតូស្ពោរីឌីយ៉ូស៊ីស គឺជាអ្វី?

គ្រីពតូស្ពោរីឌីយ៉ូស៊ីស គឺជាជម្ងឺពោះវៀនមួយ បង្កឡើងដោយមេរោគតូចក្រៃលែងមួយ ដែលអាចឆ្លងក្នុងលាមករបស់មនុស្ស ឬសត្វ ដែលមានមេរោគនេះ ។ ទាំងជម្ងឺ និងមេរោគ ហៅកាត់ថា "គ្រីពតូ" ។ មេរោគនេះការពារដោយសំបកខាងក្រៅ ដែលជួយវារស់នៅខាងក្រៅរូបកាយអស់រយៈពេលដ៏យូរ ហើយជួយវាឱ្យទប់ទល់នឹងការសម្លាប់មេរោគដោយធាតុក្លរីន ។

### តើមេរោគគ្រីពតូ ត្រូវឆ្លងតាមរបៀបអ្វីខ្លះ?

គ្រីពតូអាចឆ្លងបានតាមរបៀបខាងក្រោមនេះ:
លេបចូលរបស់ណា ដែលបានប៉ះនឹងលាមករបស់មនុស្ស ឬសត្វ ដែលមានមេរោគគ្រីពតូ

- លេបចូលទឹក ដែលមានមេរោគគ្រីពតូ ពីអាងហែលទឹក អាងមុជទឹកក្ដៅ បឹង ទន្លេ ជ្រោះ
- ស្រះ ឬអូរ ដែលពុលលាមក
- បរិភោគអាហារស្ងើរឆ្អិន ដែលពុលមេរោគគ្រីពតូ

### តើជម្ងឺនេះអាចមានរោគសញ្ញាអ្វីខ្លះ?

ធម្មតា រោគសញ្ញានៃគ្រីពតូចាប់ផ្ដើម 2-10 ថ្ងៃក្រោយពីការឆ្លង ហើយជម្ងឺមានអស់រយៈពេល2 អាទិត្យ ។ ជារឿយៗ រោគសញ្ញាចុះឡើងៗ គឺជួនពេលអ្នកជម្ងឺមានអារម្មណ៍គ្រាន់ រួចហើយលាប់វិញម្ដងទៀត រាល់ពីបីអាទិត្យម្ដង រហូតដល់អស់ជម្ងឺ ។ ធម្មតា មេរោគនៅតែមាននៅក្នុងលាមកអស់រយៈពីខែក្រោយមកទៀត ហើយក្នុងពេលនេះ វាអាចឆ្លងទៅអ្នកដទៃបាន ។
រោគសញ្ញាអាចមានរួមទាំង:

ក្រពះមិនស្រួល

រមួលចុកក្រពះ

រាគអាចម៍

ក្ដៅខ្លួនតិចៗ

អ្នកខ្លះមិនមានរោគសញ្ញាសោះ ។ ឯអ្នកខ្លះទៀតដែលមានប្រព័ន្ធស៊ាំជម្ងឺខ្សោយ មានគ្រោះថ្នាក់កើតជម្ងឺដ៏ធ្ងន់ជាង ។

ឧទាហរណ៍នៃអ្នកដែលមានប្រព័ន្ធស៊ាំដ៏ខ្សោយ គឺមានរួមទាំង: អ្នកជម្ងឺ HIV/AIDS អ្នកជម្ងឺមហារីក អ្នកទទួលសរីរាង្គពីអ្នកដទៃ ហើយនិងអ្នកដែលមានជម្ងឺរ៉ាំរ៉ៃដទៃទៀត ។

### តើជម្ងឺគ្រីពតូត្រូវបានវនិច្ឆ័យរោគយ៉ាងដូចម្ដេច?

ជម្ងឺគ្រីពតូត្រូវបានវិនិច្ឆ័យរោគ ដោយពិនិត្យលាមក ។ ប្រហែលជាត្រូវការពិនិត្យលាមកបួន ឬដប់ដង ក្នុងរយៈពេលបួន ឬដប់ថ្ងៃ ។

### តើជម្ងឺគ្រីពតូ ត្រូវបានព្យាបាលយ៉ាងដូចមដេច?

គ្មានការថ្នាំអង់ទីប៊ីយ៉ូទិកជាក់លាក់ណា សម្រាប់ព្យាបាលជម្ងឺគ្រីពតូទេ ។ មនុស្សភាគច្រើនដែលមានប្រព័ន្ធស៊ាំជម្ងឺដ៏ល្អរឹងមាំ នោះនឹងជាសះស្បើយដោយខ្លួនឯង ។ អ្នកដែលមានសុខភាពខ្សោយ គឺមានគ្រោះថ្នាក់ច្រើនជាង ហើយអាចត្រូវការដេកមន្ទីរពេទ្យក៏ថាបានដែរ ។ ថ្នាំប្រឆាំងជម្ងឺរាគ អាចប្រើប្រាស់ម្ដងមួយពេលក៏បាន ប៉ុន្តែត្រូវពិគ្រោះជាមួយនឹងពេទ្យមុនដំបូងសិន ។

### តើអាចបង្ការជម្ងឺគ្រីពតូបាន យ៉ាងដូចម្ដេច?

- លាងដៃដោយសាប៊ូ និងទឹក ក្រោយពីបទជើង ដូរកន្ទបក្មេង ហើយនិងមុនអ្នករៀបចំម្ហូប និងភេសជ្ជៈ
- ចៀសវាងទឹក និងអាហារ ដែលអាចមានមេរោគ
- ចៀសវាងកុំឱ្យផឹកទឹកពីបឹង ទន្លេ ជ្រោះ ស្រះ ឬអូរ លើកលែងតែទឹកនេះត្រូវបានសម្អាតដោយជាតិគីមីសិន
- ដាំទឹកដែលមិនបានសម្អាតឱ្យបានពុះ អស់រយៈពេលមួយនាទី ដើម្បីសម្លាប់មេរោគគ្រីពតូស្ពោរីឌីយ៉ូស៊ីស
- ចៀសវាងកុំឱ្យហែលទឹកអស់រយៈពេលពីរអាទិត្យក្រោយពីអ្នកឈប់រាគអាចម៍ បើអ្នកឆ្លងជម្ងឺគ្រីពតូ

### សម្រាប់ព័ត៌មានបន្ថែមអំពីជម្ងឺគ្រីពតូស្ពោរីឌីយ៉ូស៊ីស ទាក់ទង:

Ottawa County Health Department
www.miOttawa.org

Center for Disease Control and Prevention
www.bt.cdc.gov/ncidod/dpd/list_crp.tm

ទូរស័ព្ទ: (888) 342-2437

12251 James St., Suite 400
Holland, MI 49424
ទូរស័ព្ទ: (616) 396-5266
ទូរសារ: (616) 393-5643
វ៉ិបសាយ: www.miOttawa.org